# សេចក្តីប្រកាសព័ត៌មានរួមរបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និងអង្គការសុខភាពពិភពលោក
## ការរកឃើញជំងឺផ្តាសាយបក្សីថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ,ថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៦

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានរកឃើញករណីក្មេងស្រីអាយុ ៣ឆ្នាំ ម្នាក់ រស់នៅក្នុងខេត្តកំពង់ស្ពឺ ដែលបានឆ្លងជំងឺផ្តាសាយបក្សី និង បានស្លាប់នៅថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៦ ។ ក្មេងស្រីនេះជាករណីជំងឺផ្តាសាយបក្សីរកឃើញដំបូងនៅក្នុង ឆ្នាំ ២០០៦ នេះ , រហូតដល់ថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៦ នេះ មានជំងឺផ្តាសាយបក្សីនៅក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ៥ ករណីហើយ ដែលក្នុងនោះ កាលពីឆ្នាំ ២០០៥ បានរកឃើញចំនួន ៤ ករណី ។

ក្មេងស្រីនេះបានចាប់ផ្តើមឈឺនៅថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៦ ដោយមានរោគសញ្ញាគ្រុនក្តៅ និង ស្ថានភាពជំងឺបានវិវត្តន៍ទៅជាសភាពធ្ងន់ធ្ងរភ្លាម១ នៅថ្ងៃទី ២០ និងបានបញ្ជូនដល់មន្ទីរពេទ្យ គន្ធបុប្ផា នៅភ្នំពេញ បន្ទាប់មកបានស្លាប់ក្នុងមន្ទីរពេទ្យនៅថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៦ ។ វត្ថុវិភាគដែលបានយកពីក្មេងស្រីនេះ បានធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រ នៅភ្នំពេញ និង បានរកឃើញថាមានវិជ្ជមានមេរោគផ្តាសាយបក្សី H5N1 , ក្មេងស្រីនេះមានទីលំនៅក្នុងស្រុកគងពិសីខេត្តកំពង់ស្ពឺ ។

ក្រុមអង្កេតស្រាវជ្រាវបានចុះទៅកន្លែងកើតហេតុ ដើម្បីអង្កេតរកប្រភពដែលអាចប៉ះពាល់ និង ស្វែងរកករណីដែលអាចកើតមានផ្សេង១ទៀត ។ អ្នកប៉ះពាល់ចំនួន ៤២ នាក់ត្រូវបានរកឃើញ និង បានយកវត្ថុវិភាគដើម្បីពិនិត្យ ។ អ្នកប៉ះពាល់ចំនួន ៤ នាក់ផ្សេងទៀត ត្រូវបានធ្វើការតាមដានសុខភាពដោយមន្ត្រីសុខាភិបាល ដោយពួកគេមានសញ្ញាគ្រុនក្តៅតិចតួច, អ្នកជំងឺ ៣ នាក់មានរោគសញ្ញាតិចតួចដែរ និង ប្រវត្តន៍ប៉ះពាល់ជាមួយសត្វបក្សីស្លាប់នៅក្នុងភូមិ ។ លទ្ធផលមន្ទីរពិសោធន៍ដែលបានយកទាំងអស់នឹងដឹងនៅដើមសប្តាហ៍ក្រោយ ។

ក្រសួងកសិកម្មកំពុងធ្វើការអង្កេតស្រាវជ្រាវរកមូលហេតុនៃការស្លាប់នៃសត្វបក្សីនៅក្នុងភូមិ, ប៉ុន្តែមានការរកឃើញថា ពិតជាមានសត្វមាន់ស្លាប់នៅក្នុងភូមិ មុនពេល និង ក្នុងពេលដែលក្មេងស្រីនេះបានឈឺ ។ ការអង្កេតបានរកឃើញថា ក្មេងស្រីនេះបានប៉ះពាល់ជាមួយមាន់ដែលឈឺ និង ងាប់ ហើយនេះអាចជាប្រភពចំលងជំងឺនេះ ។ មន្ត្រីសុខាភិបាលកំពុងបន្តការតាមដានសកម្មរកករណីថ្មីផ្សេង១ទៀតនៅក្នុងភូមិ និង ធ្វើការអប់រំប្រជាជនដែលរស់នៅក្នុងតំបន់នោះ ។ មណ្ឌលសុខភាព នៅក្នុងស្រុកប្រតិបត្តិក៏កំពុងស្ថិតនៅក្នុងស្ថានភាពត្រៀមជានិច្ចក្នុងការឃ្លាំមើលរុករកប្រជាជនដែលមានរោគសញ្ញាផ្តាសាយ បក្សីលើមនុស្ស ។

----------------

**ព័ត៌មានបន្ថែមសូមទាក់ទង:**


**ក្រសួងសុខាភិបាល : វេជ្ជ. សុខ ទូច : ០១២ ៨៥៦ ៨៤៨ វេជ្ជ. លី សុវ៉ាន់ : ០១២ ៨២៥ ៤២៤**

**អង្គការសុខភាពពិភពលោក : វេជ្ជ. ម៉ៃឃល អូលីវ : ០១២ ៩៧៦ ៩៧៦ វេជ្ជ. មែក មីលឡឺ : ០១២ ៤៤៣ ៨៧៧**